**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយសាលាដំបូង **សាធារណៈ / Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោក ស សុវាន

លោក Jacques VERGES

លោក Philippe GRECIANO

**ផ្ញើជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម Mme Silvia CARTWRIGHT

ចៅក្រម យូ អូតារ៉ា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីនៃដើមបណ្តឹងរដ្ឋប្បវេណី**

លោក ពេជ្រ អង្គ

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 23 / 02 / 2011
ម៉ោង (Time/Heure): 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោកស្រី Elisabeth SIMONNEAU FORT

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

១. យោងតាមដីកាសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ("ដីកាសម្រេច") ដោយអនុវត្តតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ("វិធានផ្ទៃក្នុង")[1] សហ-ព្រះរាជអាជ្ញាបានដាក់បញ្ជីសាក្សី អ្នកជំនាញរបស់ខ្លួន និងដើមបណ្តឹងរដ្ឋប្បវេណី ("បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា") ដែលត្រូវបានជូនដំណឹងជាភាសាអង់គ្លេស និងជាភាសាខ្មែរតែប៉ុណ្ណោះ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១[2]។

២. ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ លោក ខៀវ សំផន បានស្នើសុំពន្យារថិរវេលាដាក់ឯកសារភស្តុតាង ("សំណើសុំពន្យារពេល")[3] និងបានសុំឲ្យអង្គជំនុំជម្រះសាលាដំបូងប្រើប្រាស់ភាសាបារាំងសម្រាប់ករណីរបស់លោក ព្រោះថា តុលាការបានយល់ព្រមឲ្យលោកប្រើប្រាស់ភាសានេះ ជាភាសាការងារ និងនីតិវិធីរួចទៅហើយ[4]។

៣. ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ លោក ខៀវ សំផន បានទទួលបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា ជាភាសាបារាំង[5] ហើយអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់លោកថា លោកមានពេលរហូតដល់ថ្ងៃទី១៨ ខែកុម្ភៈ ដើម្បីដាក់បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ[6]។

---

[1] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារលេខ E9 ("ដីកាសម្រេច")

[2] Co-Prosecutor's Rule 80 Expert, Witness and Civil Party Lists, including Confidential Annexes 1, 2, 3, 3A, 4 and 5, ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ឯកសារលេខ E («បញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា")។

[3] ការស្នើសុំពន្យារពេលដាក់ឯកសារភស្តុតាង ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារលេខ E9/6

[4] *Ibidem*, កថាខណ្ឌទី៣ លិខិតរបស់ក្រុមមេធាវីរបស់ លោក ខៀវ សំផន ជូនចំពោះអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងការជូនដំណឹងជាភាសាបារាំង ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារលេខ E38

[5] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និង និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា ដោយអនុវត្តតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ដែលមានឧបសម្ព័ន្ធសម្ងាត់ 1, 2, 3, 3A, 4 et 5 ឯកសារលេខ E9/4 បកប្រែនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១។

[6] Notification of Trial Chamber's disposition of Request for extension of deadlines, 14 février 2011, Doc. N° E9/6/1 ; Notification de la version française le 15 février.

៤. លោក ខៀវ សំផន ត្រូវបានបង្ខំឱ្យដាក់ឯកសារភស្តុតាងដំបូងរបស់លោកនៅថ្ងៃនេះ[7] ដែលការធ្វើបែបនេះ មិនត្រឹមតែជាការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់លោកប៉ុណ្ណោះទេ[8] ថែមទាំងបំពានលើគោលការណ៍ដែលថា ថិរវេលាកំណត់ទាំងស្រុងសម្រាប់រូបលោកត្រូវចាប់ផ្តើមគិតពីថ្ងៃជូនដំណឹងឯកសារជាភាសាបារាំងប៉ុណ្ណោះទៀតផង។ ជាក់ស្តែង លោក ខៀវ សំផន គួរតែទទួលបានពេលវេលាចំនួន ១៥ថ្ងៃ បន្ទាប់ពីថ្ងៃដាក់បញ្ជីឈ្មោះជាភាសាបារាំង របស់សហព្រះរាជអាជ្ញា (ពោលគឺ រហូតដល់ថ្ងៃទី១ មិនា ២០១១) គឺមិនមែន ៤ ថ្ងៃ (បន្ទាប់ពីបានទទួលការជូនដំណឹង ថ្ងៃទី១៤ កុម្ភៈ ២០១១) ដូចដែលអង្គជំនុំជម្រះសាលាដំបូងបាន "យល់ព្រមអនុញ្ញាត" នោះឡើយ។[9]

៥. បើយោងទៅលើអ្វីដែលទើបតែសង្កេតឃើញនេះ នៅដំណាក់កាលនេះ លោក ខៀវ សំផន មិនមានលទ្ធភាពសោះក្នុងការដឹងឱ្យច្បាស់ថា តើឯកសារភស្តុតាងណាខ្លះដែលជាគ្រឹះសម្រាប់ការការពារក្តីរបស់លោកឡើយ ជាពិសេស បើពិនិត្យលើភាពខ្វះចន្លោះក្នុងកិច្ចការរបស់សហព្រះរាជអាជ្ញា និងការងារដ៏យឺតយ៉ាវរបស់តុលាការនេះ។ ឱ្យគាត់ជ្រើសរើសសាក្សី និងអ្នកជំនាញ ក្នុងលក្ខខណ្ឌតាមអំពើចិត្តបែបនេះ គឺពិតជាមិនត្រឹមត្រូវសោះ ហើយបង្កគ្រោះថ្នាក់ដល់ការងារយុត្តិធម៌ដែលគ្រប់គ្នាកំពុងរង់ចាំទៀតផង។ បញ្ជីឈ្មោះដែលនឹងដាក់នាពេលនេះ (ឧបសម្ព័ន្ធ១ ១ស្ទួន និង២) សុទ្ធតែមានលក្ខណៈ**មិនពេញលេញ និងជាបណ្តោះអាសន្ន**។

៦. លោក ខៀវ សំផន មិនមានព័ត៌មានអប្បបរមា ពាក់ព័ន្ធនឹងភស្តុតាងដាក់បន្ទុកឡើយ។ ដោយកង្វះខាតពេលវេលា លោកក៏មិនមានពត៌មានគ្រប់គ្រាន់ អំពីមនុស្សដែលបានស្នើឡើង ជាពិសេសគឺពីអ្នកជំនាញដែលថា មានពេលអាចចូលរួមបាន។ ព័ត៌មានមួយចំនួន

[7] ថ្ងៃសុក្រទី១៨ ខែកុម្ភៈ ឆ្នាំ២០១១ ជាថ្ងៃបូណ្យកំណត់ដោយ អ.វ.ត.ក ៖ សេចក្តីណែនាំអនុវត្តន៍ ECCC/01/2007/Rev. 5 ទាក់ទិននឹងការដាក់ឯកសារ កថាខណ្ឌទី២.៣

[8] លោក ខៀវ សំផនបានបង្ហាញថា អនុវត្តតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជាការរំលោភលើសិទ្ធិជាមូលដ្ឋាន សិទ្ធិស្មធារណ៍និរទោស គោលការណ៍ដែលថាភស្តុតាងដាក់បន្ទុកលើពិរុទ្ធភាពត្រូវធ្លាក់ទៅលើក្រុមដើមចោទ សិទ្ធិស្មើភាពក្នុងការទទួលបានថិរវេលានិងការបង្កភាពងាយស្រួលចាំបាច់សម្រាប់ការពារក្តី សិទ្ធិក្នុងការទទួលបានការកាត់សេចក្តីមិនឱ្យលើសពេលកំណត់ហួសហេតុពេក។

[9] សេចក្តីជូដំណឹងស្តីពីវិធានការដែលចាត់ចែងឡើងដោយអង្គជំនុំជម្រះសាលាដំបូង ឆ្លើយទៅនឹងការសុំពន្យារថិរវេលា ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារលេខ E9/6/1 កថាខណ្ឌទី២ នៃអនុស្សារណៈ។

ដូចជា កាលបរិច្ឆេទ និងទីកន្លែងកំណើត អាសយដ្ឋាន ប្រភេទនៃសម្បថ និងខ្សែលោហិត (តាមវិធាន ២៤ នៃវិធានផ្ទៃក្នុង) នឹងអាចបញ្ជាក់បង្ហាញថែមទៀតនាពេលសវនាការ។

៧. លោក ខៀវ សំផន ទទួចលើការដែលសូមឲ្យអង្គជំនុំជម្រះសាលាដំបូង ឲ្យគាត់តែងតាំងអ្នកជំនាញ ដែលហៅថា អ្នកមិនមែនជាភាគីក្នុងរឿងក្តី ប្រសិនបើពួកគេចង់ចូលរួម ឬប្រសិនបើប្រយោជន៍នៃសុវត្ថិភាពគតិយុត្តតម្រូវឲ្យមាន។ ដូច្នេះ ចាំបាច់ត្រូវធានាឲ្យមានឯករាជ្យភាព និងភាពចាំបាច់បំផុត ក្នុងការស្វែងរកការពិត ដើម្បីជាសវាងនូវរាល់ការបន្តុំយុត្តិធម៌ទាំងឡាយ។

៨. ទីបញ្ចប់ លោក ខៀវ សំផន ចង់បានព័ត៌មានសំខាន់ៗទាំងអស់ទាក់ទងនឹងរយៈពេលសម្រាប់ធ្វើការសាកសួរសាក្សី និងអ្នកជំនាញរបស់គាត់ (សម្រាប់មេធាវីការពារក្តី)។ ហេតុនេះ រយៈពេលដែលបានលើកឡើងនេះគ្រាន់តែជាស្មាន ក្នុងន័យទូលាយប៉ុណ្ណោះ។

៩. លោកក៏សូមផ្តល់ព័ត៌មានជូនអង្គជំនុំជម្រះ ពីស្ថានភាពនៃសាក្សីដែលភ័យខ្លាចមិនហ៊ានមកបង្ហាញខ្លួនចំពោះមុខតុលាការ បើទោះបីមានវិធានការការពារក្តី។ លោក ខៀវ សំផន សុំឱកាស និងពេលវេលាដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅទៅលើបញ្ហាចោទទាំងនោះ។

១០. ម្យ៉ាងទៀត លោកបានបញ្ជូនទៅអង្គជំនុំជម្រះនូវបញ្ជីឈ្មោះសាក្សីមួយចំនួនដែលមានស្រាប់នៅក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាផងដែរ (ឧបសម្ព័ន្ធ ១ ស្ទួន) ។ លោក ខៀវ សំផន ត្រូវតែអាចសួរដេញដោលជនទាំងនោះបានដោយពេញលេញ ដោយមិនចាំបាច់ត្រូវពាក់ព័ន្ធទៅនឹងចំណុចទាំងឡាយនៃអង្គច្បាប់ និងអង្គហេតុ ដែលសហព្រះរាជអាជ្ញាបានកម្រិតកំណត់ជាឯកតោភាគី ព្រមទាំងចំណុចនានាដែលអាចនឹងមិនត្រូវបានលើកឡើងដោយតុលាការឡើយ។ ក្នុងន័យទូលាយ លោក ខៀវ សំផន ប្រាថ្នាចង់បាននូវលទ្ធភាពក្នុងការចោទសួរដោយពេញលេញ ទៅអ្នកទាំងឡាយដែលមានឈ្មោះនៅលើបញ្ជីរបស់ភាគីទាំងអស់ ។

១១. អង្គជំនុំជម្រះពិតជាដឹងយ៉ាងច្បាស់ណាស់ថា ដោយអនុលោមទៅតាមវិធាន ៨៤(១) នៃវិធានផ្ទៃក្នុង លោក ខៀវ សំផន មានសិទ្ធិទាមទារឲ្យកោះហៅសាក្សីម្នាក់មកបង្ហាញខ្លួនដែលលោកមិនទាន់មានឱកាសបានជួបតទល់ នៅក្នុងដំណាក់កាលស៊ើបអង្កេត។

១២. រាល់ការកត់សម្គាល់នេះត្រូវបានធ្វើឡើង ដើម្បីធានាសុវត្ថិភាពគតិយុត្តិនៃនីតិវិធី និងក្នុងបំណងប្រាថ្នាចង់បាន សច្ចធម៌ជូនសហគមន៍អន្តរជាតិ និងប្រជាជនកម្ពុជា។

## ហេតុដូច្នេះ

១៣. សូមអង្គជំនុំជម្រះសាលាដំបូង មេត្តា៖

- ទទួលស្គាល់ថា ការអនុវត្តវិធាន ៨០ នៃវិធានផ្ទៃក្នុង រំលោភទៅលើគោលការណ៍សន្មតថា គ្មានទោសរបស់លោក ខៀវ សំផន ដែលតាមគោលការណ៍នេះ បន្ទុកនៃភស្តុតាងត្រូវធ្លាក់លើអយ្យការ។ ការអនុវត្តនេះក៏រំលោភផងដែរទៅលើសិទ្ធិទទួលបានពេលវេលា និងភាពងាយស្រួលដ៏ចាំបាច់នានា ដើម្បីរៀបចំការការពារក្តីរបស់លោក ដោយស្មើភាពជាមួយនឹងការងារ និងដំណើរការរបស់សហព្រះរាជអាជ្ញា និងលើសិទ្ធិរបស់លោកក្នុងការទទួលបានការវិនិច្ឆ័យ ក្នុងរយៈពេលមួយមិនយឺតយ៉ាវជ្រុលពេក
- ទទួលស្គាល់ថា ព្រះរាជអាជ្ញាមិនសូវយកចិត្តទុកដាក់លើការងារ ដែលយឺតយ៉ាវក្នុងការបញ្ជូនបញ្ជីឈ្មោះរបស់ខ្លួនជា ភាសាបារាំង
- ទទួលយកបញ្ជីបណ្តោះអាសន្ននៃសាក្សី និងអ្នកជំនាញ របស់លោក ខៀវ សំផន
- អនុញ្ញាតឲ្យលោក ខៀវ សំផន កែប្រែបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ នៅពេលក្រោយ
- អនុញ្ញាតឲ្យលោក ខៀវ សំផន ស្នើសុំកោះហៅសាក្សី ដែលតម្រូវឲ្យមានការចាត់វិធានការណ៏ការពារ
- អនុញ្ញាតឲ្យលោក ខៀវ សំផន ធ្វើការចោទសួរឲ្យបានពេញលេញ ទៅកាន់សាក្សីដែលមានឈ្មោះនៅក្នុងឧបសម្ព័ន្ធ ១ ស្ទួន ដោយមិនចាំបាច់ត្រូវពាក់ព័ន្ធនឹងអង្គច្បាប់ និងអង្គហេតុដែលកម្រិតដោយសហព្រះរាជអាជ្ញាឡើយ
- អនុញ្ញាតឲ្យលោក ខៀវ សំផន សួរសាក្សីទាំងឡាយដែលមានឈ្មោះបញ្ជីរបស់គ្រប់ភាគីនានា យ៉ាងពេញលេញ

- សម្រេចថា អាចតែងតាំងអ្នកមិនមែនជាគូភាគីក្នុងរឿងក្តី ក្នុងបញ្ជីអ្នកជំនាញដែលបានដាក់ ឬ អ្នកដទៃទៀតដែលត្រូវបានទទួលស្គាល់ក្នុងឆាកអន្តរជាតិ ថា មានជំនាញខាងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ប្រវត្តិសាស្ត្រ ច្បាប់ និងទំនាក់ទំនងអន្តរជាតិ ទស្សនវិជ្ជា និងសិទ្ធិមនុស្ស។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**

**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| | មេធាវី ស សូវាន | ភ្នំពេញ | [signature] |
| [initials] | មេធាវី Jacques VERGÈS | ប៉ារីស | [signature] |
| [initials] | មេធាវី Philippe GRECIANO | ប៉ារីស | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |